**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ០៥ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ៣០,០១៩៥ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីគម្រប ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣០៨ ល.ស ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៣០,០១៩៥ ហិកតា ចេញពីដីតម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ២៦.៦៧៦២ ហិកតា សម្រាប់ប្រទានកម្មដីជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៣,៣៤៣៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិវត្តពោធិ៍ ឃុំថ្មី ស្រុកទឹកឈូ ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិវត្តពោធិ៍ ឃុំថ្មី ស្រុកទឹកឈូ ខេត្តកំពត ។



www.pheakdeylaw.com

**មាត្រា ៣:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p



www.pheakdeylaw.com

ឧបសម្ព័ន្ធ............នៃអនុក្រឹត្យលេខ...០៥.....អនក្រ.បក.............ចុះថ្ងៃទី..០៦...ខែ..មករា...ឆ្នាំ ២០១៨ ស្តីពី

ការកាត់ដីទំហំ ៣០.០១៩៥ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគ

ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៨ គ្រួសារ

និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




| ចំណុច | Y_PROJ | X_PROJ | ចំណុច | Y_PROJ | X_PROJ |
|---|---|---|---|---|---|
| 001 | 1180568 | 413533 | 050 | 1181623 | 413785 |
| 002 | 1180567 | 413505 | 051 | 1181654 | 413828 |
| 003 | 1180549 | 413504 | 052 | 1181674 | 413913 |
| 004 | 1180570 | 413485 | 053 | 1181770 | 414045 |
| 005 | 1180566 | 413482 | 054 | 1181762 | 414059 |
| 006 | 1180569 | 413479 | 055 | 1181764 | 414077 |
| 007 | 1180549 | 413477 | 056 | 1181720 | 414080 |
| 008 | 1180548 | 413469 | 057 | 1181713 | 414124 |
| 009 | 1180548 | 413469 | 058 | 1181692 | 414124 |
| 010 | 1180548 | 413455 | 059 | 1181680 | 414170 |
| 011 | 1180560 | 413457 | 060 | 1181600 | 414166 |
| 012 | 1180565 | 413434 | 061 | 1181556 | 414167 |
| 013 | 1180580 | 413433 | 062 | 1181563 | 414164 |
| 014 | 1180580 | 413380 | 063 | 1181529 | 414046 |
| 015 | 1180588 | 413361 | 064 | 1181516 | 413990 |
| 016 | 1180580 | 413352 | 065 | 1181529 | 413929 |
| 017 | 1180586 | 413297 | 066 | 1181476 | 413931 |
| 018 | 1180562 | 413266 | 067 | 1181476 | 413932 |
| 019 | 1180567 | 413234 | 068 | 1181503 | 413934 |
| 020 | 1180571 | 413246 | 069 | 1181501 | 413789 |
| 021 | 1180613 | 413220 | 070 | 1181473 | 413795 |
| 022 | 1180621 | 413285 | 071 | 1181464 | 413779 |
| 023 | 1180705 | 413330 | 072 | 1181440 | 413774 |
| 024 | 1180740 | 413382 | 073 | 1181419 | 413742 |
| 025 | 1180793 | 413417 | 074 | 1181413 | 413737 |
| 026 | 1180830 | 413444 | 075 | 1181408 | 413739 |
| 027 | 1180833 | 413465 | 076 | 1181400 | 413736 |
| 028 | 1180828 | 413487 | 077 | 1181386 | 413738 |
| 029 | 1180842 | 413514 | 078 | 1181355 | 413699 |
| 030 | 1180884 | 413544 | 079 | 1181351 | 413701 |
| 031 | 1180907 | 413565 | 080 | 1181324 | 413675 |
| 032 | 1180940 | 413580 | 081 | 1181264 | 413702 |
| 033 | 1181014 | 413591 | 082 | 1181205 | 413706 |
| 034 | 1181035 | 413592 | 083 | 1181161 | 413706 |
| 035 | 1181089 | 413575 | 084 | 1181121 | 413709 |
| 036 | 1181102 | 413579 | 085 | 1181081 | 413709 |
| 037 | 1181159 | 413566 | 086 | 1181028 | 413704 |
| 038 | 1181192 | 413546 | 087 | 1180986 | 413701 |
| 039 | 1181231 | 413528 | 088 | 1180928 | 413679 |
| 040 | 1181290 | 413504 | 089 | 1180901 | 413672 |
| 041 | 1181339 | 413484 | 090 | 1180867 | 413665 |
| 042 | 1181547 | 413412 | 091 | 1180842 | 413632 |
| 043 | 1181602 | 413484 | 092 | 1180816 | 413628 |
| 044 | 1181636 | 413509 | 093 | 1180806 | 413612 |
| 045 | 1181628 | 413523 | 094 | 1180766 | 413621 |
| 046 | 1181627 | 413541 | 095 | 1180743 | 413617 |
| 047 | 1181642 | 413601 | 096 | 1180721 | 413606 |
| 048 | 1181660 | 413603 | 097 | 1180658 | 413576 |
| 049 | 1181604 | 413734 | 098 | 1180599 | 413543 |




## សញ្ញាសម្គាល់

- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៣០.០១៩៥ ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ២៦.៦៧៦២ ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ៣.៣៤៣៣ ហិកតា
- ផ្លូវទឹក
- ផ្លូវ

**ទិន្នន័យគម្របព្រៃឈើឆ្នាំ២០០២**

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM
Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:7,000

0 87.5 175 350 525 700 Meters